10/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ១៨២៦
ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥
ជនុំជម្រះលេខ ២៧៨៣
ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥
សាលក្រមសម្រេចមុនអង្គសេចក្តី
លេខ ២៥ "ទ" ក្រ៣
ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ វេលាម៉ោង ៨ និង ០០ នាទី ព្រឹក ដោយមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោកជំទាវ [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើការស្នើសុំនៅក្រៅឃុំដោយផ្ទាល់មាត់នាពេលសវនាការ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] NASWALL (ប្រាយអិន ដាវីដ ណាស្វែល) ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក មុខរបរ ម្ចាស់ភាគហ៊ុនអាកាសចរ AERO CAMBODIA AIRLING ទីកន្លែងកំណើតនៅទីក្រុង Winnipig ខេត្ត Manatoba ប្រទេសកាណាដា មានទីលំនៅស្នាក់នៅផ្ទះជួលលេខ២០ បុរីកីឡ [redacted]២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted](លែងលះ) មានកូន ០១ នាក់ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥ ,ឃុំខ្លួនថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥

ពីបទការទិញសេវាផ្លូវភេទកុមារ ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ ២០១៥ និងជាក់ស្តែងនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

លោកស្រី [redacted] ទិមានចំប៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡើន ភេទស្រី អាយុ ៣៧ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] ស្រុកស្នួល ខេត្តក្រចេះ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ូហាន់នី ភេទស្រី អាយុ ៣៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំ [redacted] ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិដ្ធល ភេទស្រី អាយុ ៣៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខុន ភេទស្រី អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា ភេទស្រី អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិ១២ (បុរីកីឡា) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រី ភេទស្រី អាយុ ៤៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃាន ភេទស្រី អាយុ ៤៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិសារាយ ឃុំបុស្សខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ ១៥ ឆ្នាំ កើតថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០០០ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅក្នុងមជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិកុមារ ( [redacted] សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] នុនីរ័ត្ន ភេទស្រី អាយុ ៥ ឆ្នាំ កើតថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១០ សញ្ជាតិខ្មែរ មាន [redacted] ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីឃីម ភេទស្រី អាយុ ៧ ឆ្នាំ កើតថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០០៨ សញ្ជាតិខ្មែរ [redacted] ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោ [redacted] សុតីនីដុតិមុន្នី ភេទស្រី អាយុ ៦ ឆ្នាំ កើតថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០៩ សញ្ជាតិខ្មែរ មាន [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ១៣ ឆ្នាំ កើតឆ្នាំ ២០០២ សញ្ជាតិខ្មែរ មានទីលំ [redacted] រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] សុគន្ធា ភេទស្រី អាយុ ១៦ ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) [redacted] ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីរ័ត្ន ភេទស្រី អាយុ ១៥ ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) [redacted] សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ ភេទស្រី អាយុ ១៣ ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) [redacted] សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីពៅ ភេទស្រី អាយុ ១៣ ឆ្នាំ កើតថ្ងៃទី ០៥ ខែកក្កដាឆ្នាំ ២០០២ សញ្ជាតិខ្មែរ (ស្នាក់នៅអង្គការសង្គ្រោះជោគវាសនាកម្ពុជា) [redacted] សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

លោកស្រី [redacted] សុនី ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៣៥៩ អយប ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។



Scanned with CamScanner

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៨៦២២ ដ.ជ.រ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ៖**

កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ វេលាប្រហែល ១៩ និង ០០ នាទី នៅចំណុចកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] NASWALL ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក បានជិះម៉ូតូដឹកឧបកុមាររងគ្រោះចំនួន បីនាក់ មានឈ្មោះ [redacted] ស្រីល័ក្ខ ភេទស្រី អាយុ ១៣ ឆ្នាំ ,ឈ្មោះ [redacted] សុភ័ក្រ ភេទស្រី អាយុ ១៦ ឆ្នាំ និងឈ្មោះ [redacted] ស្រីរ័ត្ន ភេទស្រី អាយុ ១៥ ឆ្នាំ ដើរលេង ហូបនំចំណី និងទិញសំភារៈផ្សេងៗឲ្យទៅជនរងគ្រោះ ។ ពេលមកដល់កោះពេជ្រកន្លែងស្ងាត់ ខាងក្រោយឃ្លាំងដាក់ឥវ៉ាន់ ជនជាប់ចោទឈ្មោះ [redacted] Naswall ក៏បានឈប់ម៉ូតូ[redacted] របស់គេចេញ ក៏ឲ្យកុមាររងគ្រោះយ[redacted]គេ រួចគេក៏[redacted] របស់កុមាររងគ្រោះវិញ ដោយកុមារីរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ ដាក់អង្គុយលើម៉ូតូ រួចជនជាប់ចោទ បានយក[redacted]ស់កុមារីរងគ្រោះវិញ ។ ជនជាប់ចោទបានសន្យាឲ្យប្រាក់ទៅកុមារីរងគ្រោះទាំងអស់នោះក្នុងមួយនាក់ៗ ចំនួនពី ១៥ ដុល្លារអាមេរិក ទៅ ២០ ដុល្លារអាមេរិក ។ ក្រោយពីជនជាប់ចោទឈ្មោះ [redacted] Naswall បានធ្វើសកម្មភាពបានប្រហែល ០៧ នាទី ក៏ត្រូវសមត្ថកិច្ចចូលទៅធ្វើការឃាត់ខ្លួនជាក់ស្តែងតែម្តង ។ កន្លងមកនៅក្នុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ២០១៥ ជនជាប់ចោទឈ្មោះ [redacted]laswall ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក ក៏ធ្លាប់បានធ្វើសកម្មភាព ដូនេះទៅលើកុមារីរងគ្រោះជាច្រើននាក់ផ្សេងទៀតមកហើយ ។

**<u>នាពេលសវនាការ</u>**

ជនជាប់ចោទឈ្មោះ [redacted] Naswall បានឆ្លើយថា ខ្លួនស្នើសុំតុលាការមេត្តាផ្តល់យុត្តិធម៌ និងធ្វើការអធ្យាស្រ័យ ដល់រូបខ្លួន ព្រមទាំងកូនរបស់ខ្លួន ដើម្បីអនុញ្ញាតិឲ្យខ្លួន បានបំពេញមុខជំនួញរបស់ខ្លួនបន្តនៅក្រៅប្រទេសកម្ពុជានេះ ។ ខ្លួនពុំអាចប្រកបមុខរបរដើម្បីរកប្រាក់ចំណូល ដូច្នេះខ្លួនពុំអាចផ្តល់ការផ្គត់ផ្គង់ដល់កូនស្រីរបស់ខ្លួនក្នុងពេលដែលខ្លួនកំពង់នៅក្នុងពន្ធនាគារនោះឡើយ ។ ខ្លួនយល់ឃើញថា តុលាការ និងធ្វើការស៊ើបអង្កេតអំពីបទល្មើសជាមុនសិន ប៉ុន្តែនៅក្នុងសង្គមសម័យនេះ ពួកគេបានធ្វើការដកហូតលិខិតឆ្លងដែន និងផ្តល់ពត៌មានដល់ស្ថានទូតអាមេរិក ដូច្នេះគាត់ពុំអាចត្រឡប់ទៅប្រទេសអាមេរិកវិញ នោះគាត់និងក្លាយជាជនអន្តោប្រវេសជាពុំខាន ។ ខ្លួនចង់បើកចំហរពីស្ថានភាពលំបាកដែលមាននៅក្នុងពន្ធនាគារសព្វថ្ងៃនេះ ។ ខ្លួនស្នើសុំឲ្យតុលាការធ្វើការសម្រេចឲ្យខ្លួនបាននៅក្រៅឃុំបណ្តោះអាសន្ន ដើម្បីឲ្យខ្លួនមានលទ្ធភាពក្នុងការប្រកបមុខជំនួញរបស់ខ្លួន ដើម្បីចិញ្ចឹមកូនស្រីរបស់ខ្លួនក្នុងអំឡុងពេលមានការកាត់សេចក្តីខ្លួន ។ នាពេលនេះ ខ្លួនសុំឲ្យតុលាការលើកពេលសវនាការរយៈពេល ០២ខែ សិន ដើម្បីឲ្យខ្ញុំបាទមានលទ្ធភាពក្នុងការជួបមេធាវី ដើម្បីពិភាក្សាក្នុងការការពាររឿងក្តីរបស់ខ្លួន ។

**មេធាវីការពារឲ្យជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋាន**

ការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់ជនជាប់ចោទ ពុំមានមូលដ្ឋានច្បាស់លាស់ទេ ពីព្រោះពេលនេះជនជាប់ចោទមានសុខភាពល្អ មានស្មារតីទទួលខុសត្រូវ ហើយជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋ មានជនរងគ្រោះច្រើន ។ គប្បីតុលាការពិនិត្យ និងសម្រេចផ្តល់យុត្តិធម៌ដល់កូនក្តីខ្លួន ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**



Scanned with CamScanner

ក្រោយពីបានស្តាប់ការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់ជនជាប់ចោទឈ្មោះ [redacted] Naswall តំណាងអយ្យការ យល់ឃើញថា ការស្នើសុំនៅក្រៅឃុំពេលនេះ ពុំមានមូលដ្ឋានណាមួយដែលគួរឲ្យតុលាការពិចារណាទេ ។ ហេតុនេះតំណាងអយ្យការ គប្បីសុំឲ្យតុលាការសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ននោះទេ ។

**មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន**

នៅពេលនេះ ខ្លួនសុំឯកភាពតាមការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់កូនក្តីខ្លួន ។

**ជនជាប់ចោទនិយាយសំដីចុងក្រោយ**

សុំឲ្យតុលាការដោះលែងខ្លួនឲ្យនៅក្រៅឃុំបណ្តោះអាសន្នផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. ការស្នើសុំនៅក្រៅឃុំដោយផ្ទាល់មាត់របស់ជនជាប់ចោទនាពេលសវនាការ នៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៦ ធ្វើឡើងត្រឹមត្រូវតាមមាត្រា ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ គប្បីតុលាការសម្រេចតាមច្បាប់

២. ជនជាប់ចោទឈ្មោះ [redacted] NASWALL ត្រូវចោទប្រកាន់ពីបទការទិញពេស្យាចារកុមារ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ ជាបទឧក្រិដ្ឋ ។ ការដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំអាចធ្វើឲ្យប៉ះពាល់ដល់នីតិវិធី នៃការជំនុំជម្រះនៅថ្ងៃក្រោយ ហេតុនេះដើម្បីរក្សាទុកជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធី និងដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មីទៀត ដើម្បីរាំងកុំឲ្យមានការគាប់សង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និង អ្នកផ្សំគំនិត គប្បីតុលាការសម្រេចមិនអនុញ្ញាតិឲ្យជនជាប់ចោទឈ្មោះ [redacted] NASWALL បាននៅក្រៅឃុំបណ្តោះទេ ។

៣. ការសុំនៅក្រៅឃុំរបស់ជនជាប់ចោទនាពេលសវនាការនេះ ពុំមានមូលដ្ឋានដែលឲ្យតុលាការពិចារណាបានទេ ។

## <u>ហេតុដូច្នេះសម្រេច</u>

១. មិនអនុញ្ញាតឲ្យជនជាប់ចោទឈ្មោះ [redacted] Naswall ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក ដែលជាប់ចោទពីបទការទិញពេស្យាចារកុមារ ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ ២០១៥ និងជាក់ស្តែងនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បាននៅក្រៅឃុំបណ្តោះអាសន្នទេ ។

២. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ។



Scanned with CamScanner

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner